# មាតិការ:

ជំពូកទី ១ បទបញ្ញត្តិទូទៅ

ជំពូកទី ២ សមាជិកភាព ការសុំចូល និងការបាត់បង់ភាពជាសមាជិក

ជំពូកទី ៣ ធនធាន

ជំពូកទី ៤ រដ្ឋបាល និងការគ្រប់គ្រងសមាគម

ជំពូកទី ៥ មុខងាររបស់គណៈកម្មាធិការ

ជំពូកទី ៦ មហាសន្និបាត

ជំពូកទី ៧ ការផ្តល់រង្វាន់កិត្តិយស

ជំពូកទី ៨ ក្រុមប្រឹក្សាវាយតម្លៃ លទ្ធផល និងស្តង់ដារ

ជំពូកទី ៩ ក្រុមប្រឹក្សាវិន័យ

ជំពូកទី ១០ ទណ្ឌកម្មខាងវិន័យ

ជំពូកទី ១១ វិសោធនកម្ម និងការរំលាយ

ជំពូកទី ១២ អន្តរប្បញ្ញត្តិ

# លក្ខន្តិកៈ
# សមាគមស្ថាបត្យករកម្ពុជា
**Cambodian Society of Architects**

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

### ប្រការ ១ ឈ្មោះ

សមាគមនេះមានឈ្មោះហៅថា **"សមាគមស្ថាបត្យករកម្ពុជា"** ដោយសរសេរកាត់ជាភាសាខ្មែរ **"សសក"** និងមានឈ្មោះជាភាសាអង់គ្លេស "Cambodian Society of Architects" សរសេរអក្សរកាត់ **"CSA"** ។ **សសក** គឺជាសមាគមដែលឯករាជ្យ ក្រៅរដ្ឋាភិបាល អព្យាក្រឹត្យ មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍នយោបាយ ក្នុងនោះមានរួមទាំងមិនផ្តល់មធ្យោបាយជា សំភារៈ ហិរញ្ញវត្ថុ ធនធានមនុស្សដើម្បីគាំទ្រគណបក្សនយោបាយ ឬគាំទ្របេក្ខភាពនយោបាយណាមួយឡើយ ។

### ប្រការ ២ ទីស្នាក់ការ

**សសក** មានទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ..........ផ្លូវលេខ........ សង្កាត់..........ខ័ណ្ឌ............ ។ **សសក** អាចមានទីស្នាក់ការសាខានៅតាមបណ្តាខេត្ត តាមតំរូវការចាំបាច់របស់សមាគម ។ ទីស្នាក់ការនេះអាចផ្លាស់ប្តូរបានតាមការសំរេចរបស់គណៈកម្មាធិការសមាគម **"គកស"** ដោយមានការជូនដំណឹងដល់ក្រសួងមានសមត្ថកិច្ចព្រមទាំងធ្វើការផ្សព្វផ្សាយតាមគ្រប់មធ្យោបាយឱ្យដល់គ្រប់សមាជិក ។

### ប្រការ ៣ គោលបំណង

**សសក** បង្កើតឡើងក្នុងគោលបំណងចំបងដើម្បីពង្រឹងវិស័យស្ថាបត្យកម្មជាតិ។ **សសក** នឹងជាមជ្ឈមណ្ឌលប្រមូលផ្តុំអ្នកដែលមានវិជ្ជាជីវៈផ្នែកស្ថាបត្យកម្ម ឬស្ថាបត្យករ ឬនគរូបនីយករ ដើម្បីរួបរួមគ្នាការពារជំនាញស្ថាបត្យកម្ម លើកកំពស់តំលៃ គុណភាព និងសមត្ថភាពស្ថាបត្យករជាតិ ។

### ប្រការ ៤ រយៈពេល

អាយុកាលនៃសមាគម **សសក** មិនមានកំណត់ ប៉ុន្តែអាចនឹងត្រូវបញ្ចប់បានតែក្នុងលក្ខខ័ណ្ឌដូចមានចែងក្នុង **ជំពូកទី ១១** តែប៉ុណ្ណោះ ។

**ប្រការ ៥ សញ្ញា និងត្រាសំគាល់**

**សសក** មានសញ្ញាសំគាល់ និងត្រាសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ដូចមានគំរូភ្ជាប់នៅក្នុងលក្ខន្តិកៈនេះ ។

**ប្រការ ៦ វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងលក្ខន្តិកៈនេះ**

**ស្ថាបត្យកម្ម** ៖ គឺសំដៅដល់សិល្បៈ និងវិទ្យាសាស្ត្រនៃការគូសវាសប្លង់ សំរាប់ការសាងសង់ ស្ថាបនាផ្សេងៗ ។ ស្ថាបត្យកម្មមានវិសាលភាពទូលំទូលាយ ចាប់តាំងពីការងារសិក្សាប្លង់ ទីក្រុង អគារពីធំរហូតដល់តូច ឬការងាររៀបចំតុបតែង សួនច្បារ ការងារតុបតែងក្នុងនិងក្រៅអគារ រហូតដល់ការងារលំអិតនៃការសាងសង់សង្ហារឹម រឺសំភារៈ របស់របរផ្សេង ៗ ។

**នគរូបនីយកម្ម** ៖ គឺសំដៅដល់ការងារទាំងឡាយដែលទាក់ទងនឹងនយោបាយ ឬការងារគ្រប់គ្រងការប្រើប្រាស់ដីធ្លី ឬប្រព័ន្ធគមនាគមន៍ ឬបរិស្ថាន ឬសេដ្ឋកិច្ច ឬសង្គម/សហគម នៅក្នុងទីក្រុង ។

**បុគ្គលដែលមានវិជ្ជាជីវៈផ្នែកស្ថាបត្យកម្ម** ៖ គឺរាល់បុគ្គលទាំងឡាយណា ដែលទទួលការបណ្ដុះបណ្ដាលក្នុងវិស័យស្ថាបត្យកម្ម តាមកំរិតផ្សេងៗ ។ បុគ្គលដែលមានវិជ្ជាជីវៈផ្នែកស្ថាបត្យកម្ម ក៏រាប់បញ្ចូលផងដែរចំពោះបុគ្គលដែលកំពុងប្រកបអាជីពនៅក្នុងវិស័យស្ថាបត្យកម្ម ឬដែលពាក់ព័ន្ធនឹងវិស័យស្ថាបត្យកម្ម ។

**ស្ថាបត្យករ** ៖ គឺរាល់បុគ្គលទាំងឡាយណាដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ក្នុងវិស័យស្ថាបត្យកម្ម ឬដែលពាក់ព័ន្ធនឹងវិស័យស្ថាបត្យកម្ម និងបានទទួលស្គាល់សមត្ថភាពថាជាអ្នកដែលមានសិទ្ធិសិក្សាគំរោង ឬសិទ្ធិចុះហត្ថលេខាលើគំរោងសិក្សាស្ថាបត្យកម្មផ្សេងៗ ។ បុគ្គលដែលជាស្ថាបត្យករ ត្រូវតែមានចុះឈ្មោះក្នុងបញ្ជី **គណៈស្ថាបត្យករ** ប្រសិនបើគណៈស្ថាបត្យករនេះត្រូវបានបង្កើតឡើងរួចហើយ ។

**នគរូបនីយករ** ៖ គឺបុគ្គលទាំងឡាយណាដែលបានទទួលការបណ្ដុះបណ្ដាលក្នុងវិស័យនគរូបនីយកម្ម ។ នគរូបនីយករ ក៏រាប់បញ្ចូលផងដែរចំពោះបុគ្គលទាំងឡាយណាដែលកំពុងប្រកបរបរវិជ្ជាជីវៈក្នុងវិស័យនគរូបនីយកម្ម ឬទាក់ទងនឹងវិស័យនគររូបនីយកម្ម ។

## ជំពូកទី២
## សមាជិកភាព ការសុំចូល និងការបាត់បង់ភាពជាសមាជិក

**ប្រការ ៧ សមាជិកភាព**

**សសក** មានសមាសភាពសមាជិកដូចតទៅ ៖

- សមាជិកគាំទ្រ
- ព្រឹទ្ធសមាជិក
- សមាជិកពេញសិទ្ធិ

- សមាជិកនិស្សិត ។

## ក- សមាជិកគាំទ្រ

សមាជិកនេះជារូបវន្តបុគ្គល ឬតំណាងនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេសដែលបានសហការ ឬបានជួយ ឧបត្ថម្ភជាសំភារៈ ថវិកា ស្មារតី ឬផ្តល់ការបណ្តុះបណ្តាល ដែលផ្តល់ផលប្រយោជន៍ចំពោះ សមាគម ឬវិស័យ ស្ថាបត្យកម្ម ។

សមាសភាពសមាជិកភាពគាំទ្រត្រូវបានស្នើរឡើង និងសំរេចដោយ **គកស** តាមរយៈការបោះឆ្នោតដោយយក សំលេង គាំទ្រយ៉ាងតិច ៥០%+១ នៃសមាជិកដែលបានចូលរួមប្រជុំ ។

សមាជិកគាំទ្រមានសិទ្ធិចូលរួម និងផ្តល់យោបល់ជូនមហាសន្និបាត ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោត និងពុំមានសិទ្ធិឈរ ឈ្មោះឱ្យគេបោះឆ្នោត និងមិនតម្រូវឱ្យបង់វិភាគទានប្រចាំឆ្នាំឡើយ ។

## ខ- ព្រឹទ្ធសមាជិក

ព្រឹទ្ធសមាជិកត្រូវតែជារូបវន្តបុគ្គល មានសញ្ជាតិជាខ្មែរ ដែលមានអតីតភាពជាសមាជិកពេញសិទ្ធិរយៈពេល យ៉ាងតិច ៣ ឆ្នាំ និងមានបទពិសោធន៍ក្នុងវិជ្ជាជីវៈស្ថាបត្យកម្ម ឬវិជ្ជាជីវៈដែលពាក់ព័ន្ធស្ថាបត្យកម្មយ៉ាងតិច ១០ឆ្នាំ ។

សមាសភាពព្រឹទ្ធសមាជិកភាពគាំទ្រត្រូវបានស្នើរឡើង និងសំរេចដោយ **គកស** តាមរយៈការបោះឆ្នោត ដោយយក សំលេង គាំទ្រយ៉ាងតិច ៥០%+១ នៃសមាជិកដែលបានចូលរួមប្រជុំ ។

ព្រឹទ្ធសមាជិកគ្រប់រូប មានសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ។

សមាជិកពេញសិទ្ធិ មានកាតព្វកិច្ចបង់វិភាគទានប្រចាំឆ្នាំតាមការកំណត់របស់មហាសន្និបាត ។

## គ- សមាជិកពេញសិទ្ធិ

សមាជិកពេញសិទ្ធិ គឺជាជនជាតិខ្មែរទាំងពីរភេទ មានសញ្ញាបត្រដែលទទួលស្គាល់តាមផ្លូវច្បាប់ជាអ្នកបញ្ចប់ការ សិក្សាផ្នែកស្ថាបត្យកម្ម ឬជាស្ថាបត្យករ ឬជានគរូបនីយករ ។

សមាជិកពេញសិទ្ធិគ្រប់រូប មានសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ។

សមាជិកពេញសិទ្ធិ មានកាតព្វកិច្ចបង់វិភាគទានប្រចាំឆ្នាំតាមការកំណត់របស់មហាសន្និបាត ។

## ឃ- សមាជិកនិស្សិត

សមាជិកនិស្សិត គឺជានិស្សិតខ្មែរទាំងពីរភេទដែលកំពុងសិក្សានៅតាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស សាលា មធ្យមសិក្សាបច្ចេកទេស ឬគ្រឹះស្ថានឧត្តមសិក្សាក្នុង និងក្រៅប្រទេស ឬជារូបវន្តបុគ្គលទូទៅ ។

សមាជិកនិស្សិតនៅតាមស្ថាប័នសិក្សានីមួយៗ ត្រូវជ្រើសតាំងប្រតិភូប្រចាំឆ្នាំរបស់ខ្លួនឱ្យនៅអម **គកស** ។

សមាជិកនិស្សិតពុំមានសិទ្ធិបោះឆ្នោត និងពុំមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ។

សមាជិកនិស្សិតពុំមានកាតព្វកិច្ចបង់វិភាគទានប្រចាំឆ្នាំឡើយ ។

**ប្រការ ៨ ការសុំចូលជាសមាជិក**

ការសុំចូលជាសមាជិក **សសក** ត្រូវបំពេញពាក្យសុំចូលជាលាយល័ក្ខអក្សរចំនួន ០១ច្បាប់ ដែលរួមមានប្រវត្តិរូបចំនួន ០១ច្បាប់ រូបថត ៤ x ៦ ចំនួន ២សន្លឹក ។

នីតិវិធី និងបែបបទនៃការដាក់ពាក្យសុំចូលជាសមាជិក **សសក** នឹងត្រូវកំណត់ដោយ **គកស** ។

**ប្រការ ៩ ប័ណ្ណសំគាល់ខ្លួន**

សមាជិក **សសក** ទទួលបានប័ណ្ណសំគាល់ខ្លួនមួយ ដែលសុពលភាពរយៈពេលបីឆ្នាំម្តង ។

**ប្រការ ១០ ការបាត់បង់សមាជិកភាព**

សមាជិកភាពអាចត្រូវបាត់បង់ដោយសារ ៖

- ការសុំលាលែងពីសមាគម
- អនិច្ចកម្ម
- មានសាលក្រមពីតុលាការបញ្ជាក់ថា មានទោសពីថ្នាក់មជ្ឈិមឡើងទៅ
- ការលុបឈ្មោះចេញពីបញ្ជីសមាជិកសមាគម តាមសេចក្តីសំរេចរបស់ **គកស** ដោយមូលហេតុមិនគោរពតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ឬដោយកំហុសធ្ងន់ធ្ងរណាដែលរកឃើញដោយក្រុមប្រឹក្សាវិន័យ ។ ប៉ុន្តែសាមីខ្លួនមានសិទ្ធិការពារខ្លួនចំពោះមុខក្រុមប្រឹក្សាវិន័យ ឬ **គកស** ។

## ជំពូកទី ៣

## ធនធាន

**ប្រការ ១១** ធនធានរបស់សមាគម **សសក** បានមកពី ៖

- ប្រាក់វិភាគទានរបស់សមាជិក ។
- អំណោយពីនីតិបុគ្គលផ្សេងៗ ពីអង្គការក្នុង ឬក្រៅរដ្ឋាភិបាល ឬពីអង្គការតំបន់ ឬអន្តរជាតិនានា ។
- អំណោយ និងអច្ច័យទាន ពីសប្បុរសជននានា ។
- ប្រាក់ចំណូលពីសកម្មភាពផ្សេងៗ របស់សមាគម ។

# ជំពូកទី ៤
# រដ្ឋបាល និងការគ្រប់គ្រងសមាគម

**ប្រការ ១២** សមាគម **សសក** ត្រូវបានដឹកនាំការងារប្រចាំថ្ងៃដោយ **គណៈកម្មាធិការសមាគម (គកស)** ដែលត្រូវជ្រើសរើសដោយការបោះឆ្នោតតាមរយៈមហាសន្និបាតសមាគម ។ **គកស** មានសមាសភាពដូចតទៅ:

- ប្រធាន ១ រូប
- អនុប្រធាន ២ រូប
- លេខា ១ រូប
- ហិរញ្ញិក ១ រូប
- សមាជិក **គកស** ដែលមានតួនាទីជាប្រធានផ្នែក មានចំនួនអាស្រ័យទៅតាមតំរូវការនៅក្នុងអាណត្តិនីមួយៗ ដែលមានរយៈពេល ៣ឆ្នាំម្តង ។
- សមាជិកគណៈកម្មាធិការ ត្រូវបានមហាសន្និបាតជ្រើសតាំងឡើងសំរាប់អាណត្តិ ៣ឆ្នាំម្តង ។
- សមាជិកគណៈកម្មាធិការអាណត្តិចាស់ អាចឈរឈ្មោះបោះឆ្នោតក្នុងអាណត្តិថ្មីបាន ។

**ប្រការ ១៣ សិទ្ធិ តួនាទី និងភារកិច្ច**

សិទ្ធិ តួនាទី និងភារកិច្ចរបស់ **គកស** មានដូចខាងក្រោម:

- រៀបចំគោលនយោបាយយុទ្ធសាស្រ្ត ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ស្ថាបត្យករ ។
- ដឹកនាំ តម្រង់ទិស និងអនុវត្តតាមរាល់សេចក្តីសំរេចរបស់មហាសន្និបាត ។
- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យស្ថាបត្យកម្ម ឬនគរូបនីយកម្ម និងចូលរួមរៀបចំច្បាប់ និងបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនិងវិស័យស្ថាបត្យកម្ម ។
- ការពារកម្មសិទ្ធិបញ្ញារបស់ស្ថាបត្យករ និងការពារការប្រកួតប្រជែងដោយយុត្តិធម៌ និងស្មើភាពគ្នារវាងស្ថាបត្យករកម្ពុជា និងស្ថាបត្យករបរទេស អោយស្របតាមច្បាប់របស់ប្រទេស ។
- រៀបចំសិក្ខាសាលា សន្និសីទ និងរៀបចំកម្មវិធីបណ្តុះបណ្តាលបន្ថែមដល់អ្នកដែលមានវិជ្ជាជីវៈស្ថាបត្យកម្ម ឬស្ថាបត្យករ ដើម្បីលើកកំពស់សមត្ថភាពវិជ្ជាជីវៈស្ថាបត្យកម្មឱ្យមានកិរិតដែលអាចទទួលស្គាល់ក្នុងក្របខ័ណ្ឌតំបន់ និងជាសាកល ។
- ស្វែងរកជំនួយឧបត្ថម្ភទ្រទ្រង់សមាគម និងតាមដាន ត្រួតពិនិត្យរាល់របាយការណ៍សកម្មភាព និងចំណូល-ចំណាយ របស់សមាគម ។

- សម្របសម្រួលរាល់កិច្ចទំនាក់ទំនងលើគ្រប់ផ្នែកជំនាញ ។
- រៀបចំ និងកោះប្រជុំមហាសន្និបាតសមាគម ។
- រៀបចំជួបជុំស្ថាបត្យករ យ៉ាងតិច ១ឆ្នាំម្តង ។

**ប្រការ ១៤** ស្ថាបត្យករដែលមានសញ្ជាតិខ្មែរ អាចឈរឈ្មោះឱ្យមហាសន្និបាត **សសក** បោះឆ្នោតជាប្រធាន ឬជាអនុប្រធាន ឬជាលេខា ឬជាហិរញ្ញិកបាន ត្រូវមានឈ្មោះក្នុងបញ្ជីសមាជិកពេញសិទ្ធិ យ៉ាងតិច ០៣(បី)ឆ្នាំ ហើយ មិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយឡើយ ។

**ប្រការ ១៥** ស្ថាបត្យករដែលមានបំណងឈរឈ្មោះឱ្យមហាសន្និបាត **សសក** បោះឆ្នោតជាប្រធាន **គកស** ត្រូវរៀបចំសមាសភាពសមាជិកគណៈកម្មាធិការបង្គោលរបស់ខ្លួន ដែលរួមមាន អនុប្រធាន ២នាក់ លេខា ១នាក់ និងហិរញ្ញិក ១នាក់ ។ បេក្ខភាពគណៈកម្មាធិការ ត្រូវរៀបចំគោលនយោបាយយុទ្ធសាស្រ្ត ផែនការ សកម្មភាព វិធីសាស្រ្តអនុវត្តការងារ និងរចនាសម្ព័ន្ធគ្រប់គ្រងសំរាប់អាណត្តិ ៣ឆ្នាំ របស់ខ្លួន ដើម្បីឱ្យមហាសន្និបាតបោះឆ្នោត ជ្រើសរើស ។

**ប្រការ ១៦** ការបោះឆ្នោតត្រូវធ្វើជាសម្ងាត់ ហើយលទ្ធផលនៃការបោះឆ្នោតអាចយកជាការបានក្នុងករណីដូចមានចែងក្នុង **ជំពូកទី ៦** ។

**ប្រការ ១៧** បេក្ខជនដែលទើបជាប់ឆ្នោតជាគណៈកម្មាធិការទាំងអស់ ត្រូវកំណត់ពេលប្រជុំដើម្បីជ្រើសតាំងសមាសភាពសមាជិក **គកស** ដែលមានតួនាទីជាប្រធានផ្នែក មានចំនួនអាស្រ័យទៅតាមតំរូវការនៅក្នុងអាណត្តិរបស់ខ្លួន។

**ប្រការ ១៨** សមាជិក **គកស** ដែលមានតួនាទីជាប្រធានផ្នែក មានសមាសភាពជាសមាជិកពេញសិទ្ធិ ឬជាសមាជិកនិស្សិត។

**ប្រការ ១៩** គណៈកម្មាធិការអាចធ្វើការប្រជុំ ១ខែម្តង ឬវិសាមញ្ញ តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ២០** ករណីដែល ប្រធាន ឬអនុប្រធាន ឬអគ្គលេខាធិការ ឬហិរញ្ញិក ណាម្នាក់ទទួលមរណភាព ឬលាឈប់ពីមុខងារ ក្នុងអាណត្តិរបស់ខ្លួននោះ **គកស** ត្រូវជ្រើសរើសអ្នកជំនួសដើម្បីបញ្ចប់អណត្តិស្របតាមលក្ខន្តិកៈ។

## ជំពូកទី ៥
## មុខងាររបស់គណៈកម្មាធិការ

**ប្រការ ២១** ប្រធានគណៈកម្មាធិការសមាគមមានភារកិច្ចៈ

- គ្រប់គ្រងសមាគម ។
- តំណាងអោយសមាគម ក្នុងទំនាក់ទំនងជាមួយរដ្ឋអំណាច អង្គការសមាគម ឬស្ថាប័នផ្សេងៗ ដែលមានការពាក់ព័ន្ធ ។
- អញ្ជើញសមាជិក សមាជិកាប្រជុំ ។
- ចុះហត្ថលេខាលើឯកសារនានា របស់សមាគម ។

**ប្រការ ២២** អនុប្រធានគណៈកម្មាធិការសមាគម ជំនួយការអោយប្រធាន និងជួសមុខប្រធានក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ ។

**ប្រការ ២៣** លេខាធិការគណៈកម្មាធិការសមាគមទទួលការងារលិខិតស្នាម និងឯកសារនានារបស់សមាគម ។

**ប្រការ ២៤** ហិរញ្ញិកទទួលខុសត្រូវគ្រប់គ្រងថវិកាចំណូលចំណាយរបស់សមាគម និងរាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុរបស់សមាគមជូនដល់ **គកស** ក្នុងមួយខែម្តង ។

**ប្រការ ២៥** ប្រធានផ្នែករបស់ **គកស** ទទួលការងារផ្សេងៗ តាមការចាត់តាំងរបស់ប្រធាន ។

## ជំពូកទី ៦
## មហាសន្និបាត

**ប្រការ ២៦** មហាសន្និបាតសាមញ្ញគឺជាការប្រជុំធំរបស់សមាជិក **សសក** ដែលប្រព្រឹត្តទៅ ៣ឆ្នាំម្តង ដោយកំណត់យកខែមេសា ។

**ប្រការ ២៧** មហាសន្និបាតវិសាមញ្ញអាចប្រជុំបានគ្រប់ពេលវេលាដែលចាំបាច់ តាមការស្នើសុំពីប្រធាន **គកស** ឬតាមការស្នើសុំពីសមាជិក ពេញសិទ្ធិចំនួន ២/៣ (ពីរភាគបី) ។

**ប្រការ ២៨** រាល់ការប្រជុំសាមញ្ញ ឬវិសាមញ្ញ ត្រូវជូនដំណឹងអោយបានទូលំទូលាយ និងតាមគ្រប់វិធីសាស្ត្រ ដល់សមាជិក **សសក** ទាំងអស់ ឱ្យបានក្នុងរយៈពេលយ៉ាងតិចបំផុត ១៥(ដប់ប្រាំ)ថ្ងៃ មុនថ្ងៃប្រជុំដោយមានភ្ជាប់របៀបវារៈច្បាស់លាស់មកជាមួយផង ។

**ប្រការ ២៩** រាល់សេចក្តីសំរេចរបស់មហាសន្និបាតនឹងទុកជាការបាន លុះត្រាតែមានការចូលរួមប្រជុំពីសមាជិកពេញសិទ្ធិចំនួនយ៉ាងតិច ២៥% និងបានទទួលសំលេងគាំទ្រភាគច្រើនដាច់ខាត ៥០%+១ នៃចំនួនសមាជិកដែលមានវត្តមានក្នុងអង្គមហាសន្និបាត ។

## ជំពូកទី ៧
## ការផ្តល់រង្វាន់កិត្តិយស

**ប្រការ ៣០** រង្វាន់កិត្តិយសមាន ២ (ពីរ) ប្រភេទ គឺ :

**រង្វាន់កិត្តិយស** អាចផ្តល់ជូនបានសំរាប់លក្ខខ័ណ្ឌដូចមានចែងក្នុង **ប្រការទី ៣១** ។

**រង្វាន់កិត្តិយសឆ្នើមបំផុត** ជារង្វាន់កិត្តិយសខ្ពស់បំផុត ដែលនឹងត្រូវផ្តល់ជូនដល់បុគ្គលឆ្នើមណា ដែលបានទទួល **រង្វាន់កិត្តិយស** ច្រើនជាងគេក្នុងរយៈពេល ៣ (បី)ឆ្នាំ ជាប់គ្នា ។

**ប្រការ ៣១** អាចផ្តល់រង្វាន់កិត្តិយសជូនដល់ស្ថាបត្យករ ឬរាល់រូបវន្តបុគ្គលឆ្នើមណាដែលមានស្នាដៃបំពេញការងារសិក្សា គំរោង និងសាងសង់ ឬចូលរួមបំពេញតួនាទី ឬវិជ្ជាជីវៈដែលពាក់ព័ន្ធវិស័យស្ថាបត្យកម្ម ប្រកបដោយលទ្ធផលល្អប្រសើរ ក្នុងការលើកស្ទួយរចនាបទស្ថាបត្យកម្មជាតិបូរាណ និងទំនើប ឬស្ថាបត្យកម្មដែលទាក់ទងនឹងការថែរក្សាបរិស្ថាន និងសង្គមរស់នៅ ។ រង្វាន់កិត្តិយសក៏អាចផ្តល់ជូនផងដែរដល់នគរូបនីយករ ឬរូបវន្តបុគ្គលឆ្នើមណា ដែលមានស្នាដៃបំពេញការងារ ឬចូលរួមបំពេញតួនាទី ឬវិជ្ជាជីវៈដែលពាក់ព័ន្ធវិស័យនគរូបនីយកម្មក្នុងន័យដើម្បីការអភិវឌ្ឍន៍ អភិរក្ស ថែរក្សាបរិស្ថានទីក្រុង និងការពារផលប្រយោជន៍ទាំងឡាយ ដើម្បីជីវិតរស់នៅដ៏ល្អប្រសើរសំរាប់ទាំងអស់គ្នា ។

**ប្រការ ៣២** បេក្ខជនដែលជាស្ថាបត្យករ ឬដែលមានវិជ្ជាជីវៈពាក់ព័ន្ធវិស័យស្ថាបត្យកម្ម ឬនគរូបនីយករ ឬបេក្ខជនដែលជានិស្សិត ដែលមានបំណងដាក់បេក្ខភាពដើម្បីទទួលរង្វាន់កិត្តិយស ត្រូវដាក់ពាក្យស្នើរសុំដោយផ្ទាល់ខ្លួន អោយស្របតាមនីតិវិធីដែលរៀបចំដោយ **គកស** ហើយនឹងត្រូវឆ្លងកាត់ការត្រួតពិនិត្យ និងវាយតម្លៃសមត្ថភាព និងលទ្ធផលការងារដោយ **ក្រុម ប្រឹក្សាវាយតម្លៃ លទ្ធផល និងស្តង់ដារ** ដែលមានសមាសភាព និងតួនាទីដូចមានចែងក្នុង **ជំពូកទី ៨** ។

**ប្រការ ៣៣** **គកស** ត្រូវរៀបចំផ្សព្វផ្សាយជាសាធារណៈ សមាសភាពសមាជិកក្រុមប្រឹក្សាវាយតម្លៃ លទ្ធផល និងស្តង់ដារ និងនីតិវិធីទាំងឡាយ និងលក្ខណៈវិនិច្ឆ័យ ជូនដល់សមាជិក **សសក** ឬអ្នកដែលមានវិជ្ជាជីវៈផ្នែកស្ថាបត្យកម្ម ឬស្ថាបត្យករ ឬនគរូបនីយករទាំងអស់ រៀងរាល់ដើមឆ្នាំនីមួយៗ ។

## ជំពូកទី ៨
## ក្រុមប្រឹក្សាវាយតម្លៃ លទ្ធផល និងស្តង់ដារ

**ប្រការ ៣៤** ក្រុមប្រឹក្សាវាយតម្លៃ លទ្ធផល និងស្នងជារ ជាក្រុមប្រឹក្សាដែលមានច្រើនផ្នែកផ្សេងៗគ្នា និងតែងតាំងឡើងសំរាប់រយៈពេល ១ ឆ្នាំម្តង។ សមាជិកក្រុមប្រឹក្សាវាយតម្លៃ លទ្ធផល និងស្នងជារ តាមផ្នែកនីមួយៗ មានសមាសភាពយ៉ាងតិច ២ នាក់ជាព្រឹទ្ធិសមាជិក **សសក** និង ៣នាក់ទៀតមកពីស្ថាប័នផ្សេងៗ ក្នុង និងក្រៅ **សសក** ។ សមាសភាពសមាជិកក្រុមប្រឹក្សាវាយតម្លៃ លទ្ធផល និងស្នងជារ នឹងត្រូវស្នើរឡើង ដោយប្រធាន **គកស** ឬដោយសមាជិកពេញសិទ្ធិរបស់ **សសក** យ៉ាងតិចចំនួន ២៥% និងសំរេចយល់ព្រម ដោយ **គកស** ។

**ប្រការ ៣៥** សិទ្ធិ និងតួនាទីរបស់ក្រុមប្រឹក្សាវាយតម្លៃ លទ្ធផល និងស្នងជារ មានដូចតទៅ :

- រៀបចំផ្សព្វផ្សាយពីនីតិវិធី និងលក្ខណៈវិនិច្ឆ័យទាំងឡាយដើម្បីអាចទទួលបានរង្វាន់កិត្តិយស ។
- គ្រប់គ្រង និងត្រួតពិនិត្យនីតិវិធីនៃការជ្រើសរើសយកគំរោង ឬបេក្ខភាពសំរាប់ផ្តល់រង្វាន់កិត្តិយស ។
- ទទួលយកសំណើរគំរោងទាំងឡាយដើម្បីធ្វើរការត្រួតពិនិត្យ និងនិងវាយតម្លៃ ។
- ត្រួតពិនិត្យ និងវាយតម្លៃលក្ខណៈពិសេសនៃគំរោង ឬលក្ខណៈពិសេសនៃលទ្ធផលការងារ និង ជ្រើសរើសបេក្ខភាពសំរាប់ផ្តល់រង្វាន់កិត្តិយស និងរង្វាន់កិត្តិយសឆ្នើមបំផុត ។
- ផ្សព្វផ្សាយជាសាធារណៈពីលក្ខណៈពិសេសនៃគំរោង ឬលក្ខណៈពិសេសនៃលទ្ធផលការងារ របស់បេក្ខជន ដែលបាននឹងត្រូវផ្តល់ជូនរង្វាន់កិត្តិយស ឬរង្វាន់កិត្តិយសឆ្នើមបំផុត ។
- សមាជិកទាំងអស់របស់ក្រុមប្រឹក្សាវាយតម្លៃ លទ្ធផល និងស្នងជារ នៃផ្នែកនីមួយៗមិនមានសិទ្ធិ ស្នើរសុំបេក្ខភាពរបស់ខ្លួនឯង ដើម្បីធ្វើរការប្រកួតប្រជែងទទួលរង្វាន់កិត្តិយស នៃផ្នែកដែលខ្លួនកំពង់ បំពេញការងារបានទេ ។

## ជំពូកទី ៩
## ក្រុមប្រឹក្សាវិន័យ

**ប្រការ ៣៦** ក្រុមប្រឹក្សាវិន័យមានសមាសភាពចំនួន ០៥(ប្រាំ)រូប ដែលត្រូវតែងតាំងឡើងដោយ ប្រធាន **គកស** ក្នុងចំណោមសមាជិកក្រុមប្រឹក្សា **គកស** ។

**ប្រការ ៣៧** ក្រុមប្រឹក្សាវិន័យមានតួនាទីដូចតទៅ :

- ទទួលបណ្តឹងតវ៉ាផ្សេងៗ ពាក់ព័ន្ធនឹងសមាជិក **សសក**
- ចូលរួមដោះស្រាយវិវាទ ដែលទាក់ទងនឹងវិជ្ជាជីវៈស្ថាបត្យកម្ម
- ដាក់ទណ្ឌកម្មខាងវិន័យ ដល់សមាជិក **សសក** ណាដែលប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ស្ថាបត្យករ ។

**ប្រការ ៣៨** ស្ថាបត្យករ ដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចដាក់ទណ្ឌកម្មរបស់ក្រុមប្រឹក្សាវិន័យ មានសិទ្ធិប្ដឹងតវ៉ាទៅប្រធាន **គកស** ។ ប្រធាន **គកស** ត្រូវចាត់តាំងសមាជិកចំនួន ០៥(ប្រាំ)រូប ផ្សេងទៀតក្រៅពីសមាសភាពក្រុមប្រឹក្សាវិន័យដើម្បីពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ានោះ ។
សេចក្ដីសម្រេចចុងក្រោយនេះជាសេចក្ដីសម្រេច បិទផ្លូវតវ៉ា ។

## ជំពូកទី ១០
## ទណ្ឌកម្មខាងវិន័យ

**ប្រការ ៣៩** ទណ្ឌកម្មខាងវិន័យរួមមាន ៖

- ការស្ដីបន្ទោស ។
- ការព្រមាន ។
- ការព្យួរសិទ្ធិជាសមាជិកមួយរយៈពេលដែលមិនអាចលើសពី ០២ (ពីរ)ឆ្នាំ ។
- ការលុបឈ្មោះចេញពីបញ្ជី **សសក** ។
- ការទទួលទណ្ឌកម្មខាងវិន័យ មិននាំឱ្យបុគ្គលនោះផុតពីការទទួលខុសត្រូវផ្នែក រដ្ឋប្បវេណី និងព្រហ្មទណ្ឌឡើយ ។

## ជំពូកទី ១១
## វិសោធនកម្ម និងការរំលាយ

**ប្រការ ៤០ វិសោធនកម្ម**

វិសោធនកម្មប្រការទាំងឡាយនៃលក្ខន្តិកៈនេះ អាចធ្វើបានតាមសេចក្ដីស្នើសុំពីៈ

- ប្រធាន **គកស** ឬសមាជិក **គកស** ចំនួនពីរភាគបី
- ពីសមាជិកពេញសិទ្ធិរបស់ **សសក** យ៉ាងតិចចំនួន ២៥%
- មហាសន្និបាតជាអ្នកសំរេចលើវិសោធនកម្មទាំងនេះ ដោយយកសំលេងភាគច្រើនដាច់ខាត ៥០%+១ នៃចំនួនសមាជិកដែលមានវត្តមាន ។

**ប្រការ ៤១ ការរំលាយ**

ការសុំរំលាយសមាគមអាចធ្វើបានតាមសេចក្ដីស្នើសុំពី:

- ប្រធាន **គកស** ឬសមាជិក **គកស** ចំនួនពីរភាគបី
- ឬពីសមាជិកពេញសិទ្ធិរបស់ **សសក** យ៉ាងតិចចំនួន ២៥%
- មហាសន្និបាតជាអ្នកសំរេចរំលាយ **គកស** ឬ **សសក** ដោយមានសមាជិកពេញសិទ្ធិចូលរួមយ៉ាងតិច ២/៣ (ពីរភាគបី) និងទទួលបានសំលេងគាំទ្រ ភាគច្រើនដាច់ខាត ៥០%+១ នៃចំនួន សមាជិកដែលមានវត្តមាន ។

**ប្រការ ៤២** មានតែមហាសន្និបាតតែមួយគត់ដែលអាចសំរេចរំលាយ **សសក** បានទៅតាមនិតិវិធីដែលមាន ។ នៅពេលដែល **សសក** ត្រូវបានរំលាយ មហាសន្និបាតត្រូវរៀបចំបង្កើតគណៈកម្មាធិការមួយដើម្បីជំរះបញ្ជីទាំងឡាយរបស់ **សសក** ។ រាល់ទ្រព្យសម្បត្តិរបស់ **សសក** ដែលនៅសល់ក្រោយពីជំរះបំណុលស្របច្បាប់របស់សមាគមរួច ត្រូវផ្ទេរប្រគល់ជូនទៅអង្គការ ឬសមាគមស្របច្បាប់ណាដែលមានគោលបំណងដូច **សសក** ឬធ្វើអំណោយទានជាលក្ខណៈមនុស្សធម៌ ។ សមាជិក **សសក** និងសមាសភាព **គកស** ទាំងអស់ក៏ត្រូវរំសាយផងដែរ នៅពេលដែលសមាគមត្រូវបានរំលាយ ។

## ជំពូកទី ១២
## អន្តរប្បញ្ញត្តិ

**ប្រការ ៤៣** លក្ខន្តិកៈនេះមានសុពលភាព ក្រោយពីមានការបោះឆ្នោតយល់ព្រមដោយអង្គមហាសន្និបាតលើកទីមួយ នៅថ្ងៃទី --- ខែ --- ឆ្នាំ ២០១០ ។

**គណៈកម្មាធិការសមាគមស្ថាបត្យករកម្ពុជា**